ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# នីតិវិធីប្រតិបត្តិស្តង់ដារ(SOP)
# ស្តីពី
# ការរៀបចំពិធីអាពាហ៍ពិពាហ៍ និងពិធីបុណ្យប្រពៃណីនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា

ផ្អែកលើមូលដ្ឋាននៃការគ្របដណ្តប់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដែលសម្រេចបានរហូតដល់ ៨៧.២៧% នៃប្រជាជនក្នុងប្រទេសសរុបប្រមាណ ១៦លាននាក់ ដើម្បីបង្កើតឱ្យបាននូវភាពស៊ាំសហគមន៍រឹងមាំមួយ និងយោងលើការវិវត្តកាន់តែប្រសើរឡើងនៃស្ថានភាពជំងឺកូវីដ-១៩ ក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបើកសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញ ប្រកបដោយការទទួលខុសត្រូវខ្ពស់ និងការរស់នៅទៅតាមគន្លងប្រក្រតីភាពថ្មី។

ដើម្បីចូលរួមចំណែកដល់ការបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញ ដោយផ្សារភ្ជាប់ជាមួយនឹងការអនុវត្តវិធានការ "៣ការពារ ៣កុំ" សំដៅបង្ការហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សហការជាមួយក្រសួងសុខាភិបាល បានរៀបចំឡើងនូវនីតិវិធីប្រតិបត្តិស្តង់ដារ(SOP) ក្នុងគោលបំណងរក្សាសុវត្ថិភាពពីការឆ្លងជំងឺកូវីដ-១៩ នៅពេលរៀបចំពិធីអាពាហ៍ពិពាហ៍ និងពិធីបុណ្យប្រពៃណីនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារដូចខាងក្រោម៖

## ១. ការស្នើសុំការអនុញ្ញាតក្នុងការរៀបចំពិធី

- ពេលស្នើសុំការអនុញ្ញាតពីអាជ្ញាធរដែនដីដើម្បីរៀបចំពិធីណាមួយ ម្ចាស់ពិធីត្រូវភ្ជាប់ទៅជាមួយលិខិតធានាអះអាងនូវការអនុវត្តវិធានការការពារការរីករាលដាលឆ្លងវីរុសកូវីដ-១៩ ឱ្យបានត្រឹមត្រូវ និងពេញលេញ។ គំរូលិខិតធានាអះអាងមានទម្រង់ជូនភ្ជាប់។

## ២. វិធានការការពារការរីករាលដាលឆ្លងវីរុសកូវីដ-១៩

### ២.១. ចំនួនអ្នកចូលរួមពិធី

- អ្នកចូលរួមពិធីត្រូវបានកំណត់ចំនួនច្រើនបំផុតត្រឹម ២០០នាក់ ដោយរាប់បញ្ចូលទាំងម្ចាស់ពិធី និងភ្ញៀវ។ ចំនួនកំណត់ខាងលើ មិនរាប់បញ្ចូលអ្នកបម្រើសេវានៅក្នុងពិធី ដូចជា ក្រុមចុងភៅ ក្រុមភ្លេង និងអ្នកបម្រើសេវាផ្សេងៗទៀតឡើយ។

### ២.២. ការរៀបចំទីតាំងពិធី

- ទីតាំងពិធីត្រូវបើកចំហទ្វារនិងបង្អួច ដើម្បីឱ្យខ្យល់និងពន្លឺចេញ-ចូលបានគ្រប់គ្រាន់ និងគួរចៀសវាងការប្រើប្រាស់ម៉ាស៊ីនត្រជាក់។
- ម្ចាស់ពិធីត្រូវបានលើកទឹកចិត្តឱ្យរៀបចំពិធីក្នុងរោងនៅបរិវេណក្រៅគេហដ្ឋាន និងនៅទីតាំងបើកចំហទូលាយផ្សេងៗទៀត ដូចជា ហាង ភោជនីយដ្ឋាន មជ្ឈមណ្ឌល ឬទីកន្លែងសមរម្យនានា។
- ការសង់រោងពិធីនៅលើចិញ្ចើមផ្លូវ និង/ឬនៅលើទ្រូងផ្លូវ ត្រូវបានហាមឃាត់ដាច់ខាត។



ទូរស័ព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

## ២.៣. ការបង្ហាញបណ្ណចាក់វ៉ាក់សាំង

- អ្នកចូលរួមក្នុងពិធីទាំងអស់ ត្រូវបង្ហាញបណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ ឬ ស្កេន QR Code របស់ក្រសួងសុខាភិបាល។ ករណីនេះត្រូវបានលើកលែងចំពោះអ្នកដែលមិនបានចាក់វ៉ាក់សាំងដោយសារបញ្ហាសុខភាព។
- ម្ចាស់ពិធី ឬអ្នកទទួលសិទ្ធិពីម្ចាស់ពិធី ត្រូវទទួលខុសត្រូវពិនិត្យបណ្ណចាក់វ៉ាក់សាំងរបស់អ្នកចូលរួមទាំងអស់។

## ២.៤. ការពាក់ម៉ាស់ វាស់ស្ទង់សីតុណ្ហភាព និងអាល់កុល/ជែលសម្អាតដៃ

- ត្រូវវាស់ស្ទង់សីតុណ្ហភាព និងប្រើអាល់កុល/ជែលសម្អាតដៃរបស់អ្នកចេញ-ចូលក្នុងបរិវេណរោងពិធី និងតម្រូវឱ្យអ្នកចូលរួមគ្រប់រូបពាក់ម៉ាស់ជានិច្ច។ ការពាក់ម៉ាស់សម្រាប់កូនកំលោះ និងកូនក្រមុំ នៅក្នុងពេលរៀបចំពិធីអាពាហ៍ពិពាហ៍ ត្រូវបានលើកលែង។
- ត្រូវមានម៉ាស់ អាល់កុល ឬជែលសម្អាតដៃ និងឧបករណ៍វាស់ស្ទង់សីតុណ្ហភាព ឱ្យបានគ្រប់គ្រាន់នៅតាមកន្លែងសំខាន់ៗ ក្នុងទីតាំងពិធី ដើម្បីឱ្យអ្នកចូលរួមពិធីអាចផ្លាស់ប្តូរម៉ាស់ សម្អាតដៃ និងតាមដានសីតុណ្ហភាពរបស់ខ្លួន បានញឹកញាប់។
- ត្រូវសម្អាតដៃនឹងអាល់កុល ឬជែលជាប្រចាំ ក្រោយបញ្ចប់កិច្ចនីមួយៗនៃពិធី។

## ២.៥. ការធ្វើតេស្តរហ័សរកវីរុសកូវីដ-១៩

- ម្ចាស់ផ្ដើមពិធី ឪពុកម្ដាយ កូនកំលោះ កូនក្រមុំ អ្នកកំដរ អ្នកក្លួង អាចារ្យ អ្នកផ្លូវចៅមហា ចុងភៅ អ្នកបម្រើសេវាម្ហូបអាហារ-ភេសជ្ជៈ អ្នកភ្លេង អ្នកចម្រៀង និងអ្នកដទៃទៀតដែលត្រូវនៅកៀកគ្នាក្នុងអំឡុងពេលកិច្ចពិធី ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ នៅមុនពេលចាប់ផ្ដើមពិធី។ ម្ចាស់ពិធី ឬអ្នកទទួលសិទ្ធិពីម្ចាស់ពិធី ត្រូវទទួលខុសត្រូវលើការអនុវត្តធ្វើតេស្តរហ័សនេះ។
- ភ្ញៀវដែលចូលរួមពិធី ត្រូវបានលើកទឹកចិត្តឱ្យធ្វើតេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ ដោយខ្លួនឯង នៅមុនពេលទៅចូលរួមពិធី។
- ក្នុងករណីសង្ស័យលើអ្នកចូលរួមពិធី ត្រូវដាក់អ្នកសង្ស័យនោះ ឱ្យនៅដាច់ដោយឡែកពីអ្នកដទៃ ធ្វើតេស្តរហ័សរកអង់ទីហ្សែនមេរោគកូវីដ-១៩ និងរាយការណ៍ជាបន្ទាន់ទៅមន្ត្រីសុខាភិបាល ។

## ២.៦. ការរក្សាគម្លាតសុវត្ថិភាព និងការកាត់បន្ថយជំនួបដោយផ្ទាល់

- ត្រូវរក្សាគម្លាតសុវត្ថិភាពអប្បបរមាក្នុងចម្ងាយ ១.៥ម៉ែត្រ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ករណីនេះត្រូវបានលើកលែងចំពោះកូនកំលោះ កូនក្រមុំ ឪពុក ម្ដាយ អ្នករស់នៅក្នុងផ្ទះជាមួយគ្នា និងអ្នកដែលត្រូវស្ថិតនៅកៀកគ្នាទៅតាមភាពចាំបាច់នៃកិច្ចពិធី ។
- កាត់បន្ថយជំនួបដោយផ្ទាល់ចំពោះកិច្ចការណា ដែលអាចអនុវត្តបានពីចម្ងាយ ដូចជា ការអញ្ជើញភ្ញៀវតាមទូរស័ព្ទ បណ្ដាញទាក់ទងសង្គម ឬមធ្យោបាយផ្សេងៗទៀត ក៏ដូចជាការចងចំណងដៃជាសាច់ប្រាក់ និងការទូទាត់សាច់ប្រាក់លើសេវាកម្មផ្សេងៗ តាមប្រព័ន្ធធនាគារ ឬសេវាផ្ទេរប្រាក់ជាដើម។

## ២.៧. ការប្រមូលផ្ដុំនិងការចល័តក្នុងបរិវេណពិធី

- ត្រូវកាត់បន្ថយការចល័តចុះឡើងញឹកញាប់របស់អ្នកចូលរួម នៅក្នុងទីតាំងប្រារព្ធពិធី ដោយដាក់បង្ហាញនូវសញ្ញានិងទិសដៅនៃការចល័តចេញ-ចូល ដោយរក្សាគម្លាតយ៉ាងតិចបំផុត ១.៥ម៉ែត្រ។

- មិនត្រូវប្រមូលផ្តុំគ្នាច្រើនកុះករនៅក្នុងពិធីណាមួយ និង/ឬនៅទីតាំងណាមួយនោះទេ ដូចជា កន្លែងតុបតែងខ្លួន ថតរូប ចុងភៅ ល។ និង ល។

## ២.៨. ការសម្អាតអនាម័យ

- ត្រូវលាងសម្អាត និងបាញ់អាកុល ឱ្យបានញឹកញាប់នៅលើទីតាំង និងកន្លែងដែលមានការប្រើប្រាស់រួមគ្នាច្រើន ដូចជា បន្ទប់ទឹក ដៃទ្វារចេញ-ចូល តុ កៅអី និងកន្លែងអង្គុយជាដើម។
- ត្រូវរៀបចំវេចខ្ចប់ និងទុកដាក់សំរាមក្នុងធុងឱ្យបានត្រឹមត្រូវ ដោយមិនត្រូវបោះសំរាមចោលនៅក្នុងបរិវេណទីតាំងពិធី។

## ២.៩. ពិធីនិងសេវាគាំទ្រពិធី

- ពិធីបែបប្រពៃណី ទំនៀមទម្លាប់ ជំនឿ និងសាសនា គឺជាពិធីចាំបាច់ដែលត្រូវបានលើកទឹកចិត្តឱ្យរៀបចំ។
- ពិធីបែបបរទេស ដូចជា កាត់នំ បោះផ្កា ក៏ដូចជាពិធីបែបបរទេសដទៃទៀត និងពិធីបន្ទាប់បន្សំផ្សេងៗ ដែលមិនចាំបាច់ គប្បីត្រូវបានកាត់បន្ថយ។
- ត្រូវប្រើប្រាស់ធនធាន សម្ភារៈ ផលិតផល និងមធ្យោបាយ ក្នុងប្រទេសឱ្យអស់លទ្ធភាព ដោយព្យាយាមកាត់បន្ថយការប្រើប្រាស់ផលិតផលពីបរទេស។

## ២.១០. ការរៀបចំអាហារ

- ត្រូវកាត់បន្ថយចំនួនអ្នកអង្គុយនៅតុអាហារ និង/ឬរៀបចំអាហារជាលក្ខណៈប៊ូហ្វេ និង/ឬរៀបចំជាកញ្ចប់ឈុតអាហារសម្រាប់មនុស្សម្នាក់ៗតែម្តង។
- ចុងភៅ អ្នកលើកម្ហូប អ្នកចាប់ទឹកកក និងអ្នកបម្រើសេវាម្ហូបអាហារ-ភេសជ្ជៈ ឬសេវាផ្សេងទៀត ទោះបីជាបានធ្វើតេស្តហើសរួចហើយក្តី ក៏ត្រូវប្រកាន់ខ្ជាប់នូវស្តង់ដាអនាម័យឱ្យបានពេញលេញ។

## ៣. កិច្ចសហការរបស់ម្ចាស់ពិធី

- ត្រូវចូលរួមសហការផ្សព្វផ្សាយនីតិវិធីប្រតិបត្តិស្តង់ដានេះ តាមរយៈការរៀបចំជាផ្ទាំងរូបភាព សារអប់រំ ឬស្លាកសញ្ញាផ្សព្វផ្សាយអំពីវិធានសុវត្ថិភាពនៅទីតាំងពិធីផ្ទាល់ និងជូនដំណឹងដល់អ្នកដែលនឹងត្រូវចូលរួមពិធីទាំងអស់ តាមរយៈលិខិតអញ្ជើញ(ធៀបការ ឬសំបុត្របុណ្យ)ជាដើម។
- ត្រូវចូលរួមសហការឱ្យបានពេញលេញជាមួយអាជ្ញាធរពាក់ព័ន្ធ ជាពិសេសអាជ្ញាធរដែនដី ក្នុងការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដានេះ ប្រកបដោយប្រសិទ្ធភាព។
- ត្រូវចូលរួមសហការអនុវត្តនូវរាល់វិធានការចាំបាច់ថ្មីៗ ដែលកំណត់ដោយក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមប្រយុទ្ធនឹងជំងឺកូវីដ-១៩៕

ថ្ងៃ.ចន្ទ..៤កើត...ខែកត្តិក...ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.៨....ខែ.វិច្ឆិកា.ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថតថ្មី
4x6

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..................................អក្សរឡាតាំង...................................ភេទ............
ជនជាតិ..................សញ្ជាតិ.................កើតថ្ងៃទី.........ខែ............ឆ្នាំ............នៅភូមិ........................
ឃុំ/សង្កាត់.......................ស្រុក/ក្រុង/ខណ្ឌ..............................ខេត្ត/រាជធានី........................ប្រទេស
........................មុខរបរបច្ចុប្បន្ន.........................ទីកន្លែងការងារ..........................អាសយដ្ឋានបច្ចុប្បន្ន
ផ្ទះលេខ.............ផ្លូវ..........................ក្រុមទី.........ភូមិ......................ឃុំ/សង្កាត់...............................
ស្រុក/ក្រុង/ខណ្ឌ..............................ខេត្ត/រាជធានី......................ទូរស័ព្ទលេខ.................................
អត្តសញ្ញាណប័ណ្ណលេខ *(ករណីជនជាតិខ្មែរ)*.........................លិខិតឆ្លងដែនលេខ *(ករណីជនបរទេស ឬគ្មានអត្តសញ្ញាណប័ណ្ណ)*
.................................... ជាម្ចាស់ពិធី *(សូមបំពេញ "អាពាហ៍ពិពាហ៍" ឬ "ពិធីបុណ្យ")*..........................................

## សូមធានាអះអាងថា

ទី១. ខ្ញុំបាទ/នាងខ្ញុំនឹងអនុវត្តឱ្យបានពេញលេញនូវរាល់វិធានការការពារការរីករាលដាលឆ្លងវីរុសកូវីដ-១៩ ដែលមានចែងនៅក្នុង "**នីតិវិធីប្រតិបត្តិស្តង់ដា(SOP)ស្តីពីការរៀបចំពិធីអាពាហ៍ពិពាហ៍និងពិធីបុណ្យប្រពៃណីនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា**" ក៏ដូចជាវិធានការថ្មីៗរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា។

ទី២. ខ្ញុំបាទ/នាងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ក្នុងករណីពុំបានអនុវត្តត្រឹមត្រូវតាមការធានាអះអាងខាងលើ។

ថ្ងៃ...............................ខែ...................ឆ្នាំ....................ព.ស............
..............................ថ្ងៃទី...........ខែ...........ឆ្នាំ.............

**ម្ចាស់ពិធី**
ស្នាមមេដៃនិងឈ្មោះ

**សាក្សី**
ស្នាមមេដៃនិងឈ្មោះ

<u>បានឃើញ</u>
ថ្ងៃ..............................ខែ.................ឆ្នាំ.....................ព.ស............
..........................ថ្ងៃទី...........ខែ...........ឆ្នាំ.............

**មេឃុំ/ចៅសង្កាត់**
ហត្ថលេខានិងត្រា